## ព្រះរាជាណាចក្រកម្ពុជា

### ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧១ . អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការលុបឈ្មោះវិទ្យាស្ថានអន្តរជាតិនៃកម្ពុជា

* * * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៧/១២៩ ចុះថ្ងៃទី៣១ ខែ មីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់ គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រង គ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការ បង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យ លេខ ៩២ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតវិទ្យាស្ថាន អន្តរជាតិនៃកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ ១១១ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការប្តូរឈ្មោះ សាកលវិទ្យាល័យអាស៊ានទៅជា សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ស ម្រេ ច

**មាត្រា ១.-**

លុបឈ្មោះគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **វិទ្យាស្ថាន អន្តរជាតិ នៃកម្ពុជា International Institute of Cambodia** ដែលមានទីតាំងស្ថិតនៅ អគារលេខ ៤៤១ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

**មាត្រា ២.-**

អនុញ្ញាតឱ្យ វិទ្យាស្ថានអន្តរជាតិនៃកម្ពុជា ផ្ទេរនិស្សិតទាំងអស់ដែលបានសិក្សា ឱ្យទៅសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ។ នៅពេលនិស្សិតទាំងនេះ រៀនចប់កម្មវិធីសិក្សា និងទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា នឹងទទួលបានសញ្ញាបត្រ តាមកម្រិតសិក្សា ដែលផ្តល់ដោយសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ និងមានការទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីអនុវត្តបានតាមគោលការណ៍ និងបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៣.-**

អនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតវិទ្យាស្ថានអន្តរជាតិនៃកម្ពុជា ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្រសួងស្ថាប័ន ពាក់ព័ន្ធ សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ និងវិទ្យាស្ថានអន្តរជាតិនៃកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០០៧*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ